# ព្រះរាជក្រឹត្យ

នស/រកត/០៩២០/៩៤៣

## យើង

### ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
### សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
### ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
### ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី ០៦ ខែកញ្ញា ឆ្នាំ ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី ៣០ ខែមីនា ឆ្នាំ ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី ២៨ ខែមិថុនា ឆ្នាំ ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១០១៧/៨២០ ចុះថ្ងៃទី២៤ ខែតុលា ឆ្នាំ២០១៧ ស្តីពីការតែងតាំង និងផ្តល់ឋានៈ ដល់មន្ត្រីរាជការ ០៤រូប នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១០១៧/៨២១ ចុះថ្ងៃទី២៤ ខែតុលា ឆ្នាំ២០១៧ ស្តីពីការតែងតាំង និងផ្តល់ឋានៈ ដល់មន្ត្រីរាជការ ០៥រូប នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១** : តម្លើងឋានៈ ដល់ មន្ត្រីរាជការនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ **៧ រូប** :

**១**- តម្លើងឋានៈស្មើ រដ្ឋលេខាធិការ ដល់ ឯកឧត្តម **មាស សុខសេនសាន** អគ្គលេខាធិការ

**២**- តម្លើងឋានៈស្មើ រដ្ឋលេខាធិការ ដល់ ឯកឧត្តម **ខេវ្យ ប៊ុនឥន្ទ្រាទុធ** ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយក នៃអគ្គនាយកដ្ឋានរតនាគារជាតិ

៣- តម្លើងឋានៈស្មើ រដ្ឋលេខាធិការ ដល់ ឯកឧត្តម **ហាច រតន:** ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋានថវិកា

៤- តម្លើងឋានៈស្មើ រដ្ឋលេខាធិការ ដល់ ឯកឧត្តម **កែវ បេងវឌ្ឍន៍** ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋានហិរញ្ញវត្ថុរដ្ឋបាលថ្នាក់ក្រោមជាតិ

៥- តម្លើងឋានៈស្មើ រដ្ឋលេខាធិការ ដល់ ឯកឧត្តម **ឈឹម សារ៉េត** ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *

៦-តម្លើងឋានៈស្មើ **រដ្ឋលេខាធិការ** ដល់ ឯកឧត្តម **នេត មុន្នី** ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយក
នៃអគ្គនាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋ **និងចំណូលមិនមែនសារពើពន្ធ**

៧-តម្លើងឋានៈស្មើ **រដ្ឋលេខាធិការ** ដល់ ឯកឧត្តម **ម៉ី ម៉ាន់** ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយក
នៃអគ្គនាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុ។

**មាត្រា ២** : សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

នស/រកត.០៩២០.៩៦៥

*ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ០៣ ខែ កញ្ញា ឆ្នាំ ២០២០*

នរោត្តម សីហមុនី

**នរោត្តម សីហមុនី**